# ឯកសារទស្សនទាន

# វគ្គបណ្តុះបណ្តាលស្តីពីជំនាញសម្របសម្រួល និងការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន

### ថ្ងៃទី ២៨ - ៣០ ខែសីហា ឆ្នាំ២០១៨ នៅភ្នំពេញ

## ១. សេចក្តីផ្តើម

តាមរបាយការណ៍សិក្សាស្រាវជ្រាវដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ក្នុងឆ្នាំ ២០១២ និងរបាយការណ៍សិក្សាស្រាវជ្រាវរបស់អង្គការអុកស្វាមក្នុងឆ្នាំ ២០១៤ បង្ហាញថា មានអង្គការសហគមន៍មូលដ្ឋានប្រមាណជាង ២៥០០០ (ពីរម៉ឺនប្រាំពាន់) ហើយពួកគាត់ដើរតួនាទីដ៏សំខាន់ក្នុងការអភិវឌ្ឍខាងផ្នែកសេដ្ឋកិច្ចសង្គម និងលើសពីនេះ។ ទោះបីជាយ៉ាងណា ការប្រតិបត្តិរបស់អង្គការសហគមន៍មូលដ្ឋាននៅប្រទេសកម្ពុជានៅតែត្រូវការការលើកកម្ពស់ និងគាំទ្រពីភាគីពាក់ព័ន្ធដទៃទៀត រួមទាំងដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងរដ្ឋាភិបាល។ ដើម្បីជាការចូលរួមក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ និងនិរន្តរភាពរបស់អង្គការសហគមន៍មូលដ្ឋាន អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ និងក្រុមការងារបច្ចេកទេស គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាននៅប្រទេសកម្ពុជាបានបង្កើតឡើង។ ទន្ទឹមនឹងនេះ ដើម្បីឲ្យអង្គការសហគមន៍មូលដ្ឋានមានសមត្ថភាពក្នុងការប្រើប្រាស់គោលការណ៍ណែនាំនេះប្រកបដោយប្រសិទ្ធភាព និងដើម្បីឆ្លើយតបទៅនឹងការសិក្សាប៉ាន់ប្រមាណតម្រូវការការកសាងសមត្ថភាព របស់អង្គការសហគមន៍មូលដ្ឋាន អង្គការគ.ស.ក ក៏បានបង្កើត **សៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន**។ សៀវភៅនេះ គឺជាកម្រងមេរៀនសម្រាប់គ្រូបង្គោលទុកជាឯកសារជំនួយក្នុងការបង្រៀនដល់អង្គការសហគមន៍មូលដ្ឋាន ឲ្យធ្វើការប្រតិបត្តិការនៅក្នុងសហគមន៍ប្រកបដោយអភិបាលកិច្ចល្អ វិជ្ជាជីវៈ និងនិរន្តរភាព ព្រោះថាខ្លឹមសារនៃមេរៀននេះ បានជួយ តម្រង់ទិស និងប្រាប់ពីរបៀបដែលអង្គការសហគមន៍មូលដ្ឋានគួរប្រតិបត្តិ ការបង្កើតលក្ខន្តិកៈ និងគោលនយោបាយផ្សេងៗ ការទំនាក់ទំនងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ ការគ្រប់គ្រងសមាជិក ការចាត់ចែង និងគ្រប់គ្រងលើធនធាន (មនុស្ស សម្ភារៈ និងហិរញ្ញវត្ថុ) ការធ្វើផែនការ និងការតាមដានត្រួតពិនិត្យលើការងារប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

ក្នុងកិច្ចអន្តរាគមន៍នេះ ដើម្បីឲ្យ **សៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន** អាចបំពេញបន្ថែមដល់សមត្ថភាពសម្របសម្រួលបន្តរបស់អង្គការសង្គមស៊ីវិល និងឆ្លើយតបទៅនឹងតម្រូវការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន អង្គការ គ.ស.ក ក៏បានរៀបចំវគ្គបណ្តុះបណ្តាលសាកល្បង ស្តីពីជំនាញសម្របសម្រួល និងការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability
GPP
25/08/2015 24/08/2018
Symbol of Trust

## ២. វគ្គបណ្តុះបណ្តាលនេះមានគោលដៅចំបងៗគឺ៖

១. ដើម្បីធ្វើការបង្រៀនសាកល្បង និងឆ្លុះបញ្ចាំង ថាតើសៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាននេះ បានឆ្លើយតបទៅនឹងតម្រូវការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន ក៏ដូចជាអង្គការសង្គមស៊ីវិលដែលធ្វើការគាំទ្រដល់អង្គការសហគមន៍មូលដ្ឋានហើយឬនៅ។

២. ដើម្បីធ្វើការកែសម្រួលសៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀននេះ ឲ្យមានភាពងាយស្រួល និងឆ្លើយតបទៅនឹងតម្រូវការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន។

## ៣. កាលបរិច្ឆេទ និង ទីកន្លែងនៃវគ្គបណ្តុះបណ្តាល

**កាលបរិច្ឆេទ៖** ថ្ងៃទី២៨ - ៣០ ខែសីហា ឆ្នាំ២០១៨ ម៉ោង ០៨៖០០ ព្រឹក ដល់ ១៧៖០០ រសៀល

**ទីកន្លែង៖** ទីកន្លែងនៅ ដាយកូនៀ សិនធ័រ (ផ្ទះលេខ ១៩-២០ ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ)

## ៤. លទ្ធផលរំពឹងទុក

១. អ្នកចូលរួមនឹងយល់ដឹងកាន់តែប្រសើរលើខ្លឹមសារនៃ **សៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន**។

២. អ្នកចូលរួមនឹងធ្វើការត្រួតពិនិត្យ និងពិភាក្សាលើខ្លឹមសារនៃ **សៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន** ដើម្បីធ្វើការកែសម្រួលសៀវភៅនេះឲ្យឆ្លើយតបទៅនឹងតម្រូវការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន

៣. **សៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន**នឹងធ្វើការកែសម្រួល ដើម្បីឲ្យសៀវភៅនេះឲ្យឆ្លើយតបទៅនឹងតម្រូវការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន

៤. អ្នកចូលរួមបានពិភាក្សា និងឯកភាពទៅលើផែនការបន្តទាក់ទងនឹងវគ្គបណ្តុះបណ្តាលនេះ

## ៥. អ្នកចូលរួម

វគ្គបណ្តុះបណ្តាលនេះនឹងមានអ្នកចូលរួមចំនួនប្រមាណពី ២៥ នាក់ ដែលជាក្រុមការងារបច្ចេកទេសរបស់អង្គការសហគមន៍មូលដ្ឋាន និងអង្គការដៃគូដែលធ្វើការគាំទ្រអង្គការសហគមន៍មូលដ្ឋានមួយចំនួនទៀត។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability គណនេយ្យភាព
GPP 25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃការទុកចិត្ត

## ៦. របៀបវារៈ

| *ម៉ោង* | *ការពិភាក្សា* | *អ្នកសម្របសម្រួល* |
|---|---|---|
| ថ្ងៃទី១៖ ថ្ងៃទី ២៨ សីហា ២០១៨ | | |
| ០៨៖០០ ដល់ ៨០៖៣០ | ចុះឈ្មោះអ្នកចូលរួម | **លោកស្រី ស្រេង សោភ័ណលក្ខិណា** ជំនួយការកម្មវិធីការអភិវឌ្ឍសមត្ថភាព |
| ០៨៖៣០ដល់ ០៨៖៤៥ | ការណែនាំអំពីគោលបំណងនៃវគ្គបណ្តុះបណ្តាល | **កញ្ញា កៅ ពៅលក្ខិណា** អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ០៨៖៤៥ ដល់ ០៩៖០០ | សន្ទរកថាស្វាគមន៍ និងបើកកម្មវិធី ដោយអង្គការ គ.ស.ក | តំណាងមកពី អង្គការគ.ស.ក |
| ០៩៖០០ដល់ ០៩៖៣០ | បទបង្ហាញជាទូទៅស្តីពី **សៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន** | **កញ្ញា កៅ ពៅលក្ខិណា** អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ០៩៖៣០ ដល់ ០៩៖៤៥ | សម្រាក និងពិសារអាហារសម្រន់ | ទាំងអស់គ្នា |
| ០៩៖៤៥ ដល់ ១១៖៣០ | ការសាកល្បងបង្រៀនជំនាញសម្របសម្រួលលើមេរៀន<br>• ការរៀបចំបរិបទនៃវគ្គបណ្តុះបណ្តាល<br>• មូលដ្ឋានគ្រឹះនៃការសម្របសម្រួល | **កញ្ញា កៅ ពៅលក្ខិណា** អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន<br><br>**លោកស្រី ស្រេង សោភ័ណលក្ខិណា** ជំនួយការកម្មវិធីការអភិវឌ្ឍសមត្ថភាព |
| ១១៖៣០ ដល់ ១២៖០០ | ការពិភាក្សាក្រុមធំ ឆ្លុះបញ្ចាំង និងមតិកែលំអអំពីមេរៀន | ទាំងអស់គ្នា |
| ១២៖០០ ដល់ ១៣៖៣០ | ពិសារអាហារថ្ងៃត្រង់ | ទាំងអស់គ្នា |
| ១៣៖៣០ ដល់ ១៥៖០០ | ការសាកល្បងបង្រៀនជំនាញសម្របសម្រួលលើមេរៀន<br>• ជំនាញសម្រាប់ការសម្របសម្រួល | **លោក ស៊ឹង ទីប៉ូ** អ្នកគ្រប់គ្រងផ្នែកអភិវឌ្ឍន៍សមត្ថភាព |

DRAFT



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability គណនេយ្យភាព GPP 25/08/2015 24/08/2018 Symbol of Trust

| | | |
|---|---|---|
| ១៥:០០ ដល់ ១៥:២០ | ការពិភាក្សាក្រុមធំ ឆ្លុះបញ្ចាំង និងមតិកែលំអអំពីមេរៀន | ទាំងអស់គ្នា |
| ១៥:២០ ដល់ ១៥:៣៥ | សម្រាក និងពិសារអាហារសម្រន់ | ទាំងអស់គ្នា |
| ១៥:៣៥ ដល់ ១៦:៤០ | ការសាកល្បងបង្រៀនមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន<br>• លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន | **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ១៦:៤០ ដល់ ១៧:០០ | ការពិភាក្សាក្រុមធំ ឆ្លុះបញ្ចាំង និងមតិកែលំអអំពីមេរៀន | ទាំងអស់គ្នា |
| ថ្ងៃទី២៖ ថ្ងៃទី ២៩ សីហា ២០១៨ | | |
| ០៨:០០ ដល់ ៨០:៣០ | រំលឹកមេរៀន និងការពិភាក្សាថ្ងៃទី១ | **លោកស្រី ស្រេង សោភ័ណលក្ខិណា**<br>ជំនួយការកម្មវិធីអភិវឌ្ឍន៍សមត្ថភាព |
| ០៨:៣០ដល់ ០៩:៣០ | ការសាកល្បងបង្រៀនមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន<br>• ទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ | **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ០៩:៣០ ដល់ ០៩:៥០ | ការពិភាក្សាក្រុមធំ ឆ្លុះបញ្ចាំង និងមតិកែលំអអំពីមេរៀន | ទាំងអស់គ្នា |
| ០៩:៥០ ដល់ ១០:០៥ | សម្រាក និងពិសារអាហារសម្រន់ | ទាំងអស់គ្នា |
| ១០:០៥ដល់ ១១:៤០ | ការសាកល្បងបង្រៀនមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន<br>• សមាជិកភាព និងការគ្រប់គ្រងសមាជិក<br>• ការគ្រប់គ្រងហិរញ្ញវត្ថុ | **លោក សុខ សុវណ្ណ**<br>អ្នកឯកទេសផ្នែកណែនាំ និងបង្វឹក |
| ១១:៤០ ដល់ ១២:០០ | ការពិភាក្សាក្រុមធំ ឆ្លុះបញ្ចាំង និងមតិកែលំអអំពីមេរៀន | ទាំងអស់គ្នា |
| ១២:០០ ដល់ ១៣:៣០ | ពិសារអាហារថ្ងៃត្រង់ | ទាំងអស់គ្នា |
| ១៣:៣០ ដល់ ១៥:០០ | ការសាកល្បងបង្រៀនមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន<br>• គណនេយ្យភាព និងតម្លាភាព | **លោក សុខ សុវណ្ណ**<br>អ្នកឯកទេសផ្នែកណែនាំ និងបង្វឹក |

DRAFT

| | | |
|---|---|---|
| ១៥៖០០ ដល់ ១៥៖២០ | ការពិភាក្សាក្រុមធំ ឆ្លុះបញ្ចាំង និងមតិកែលំអអំពីមេរៀន | ទាំងអស់គ្នា |
| ១៥៖២០ ដល់ ១៥៖៣៥ | សម្រាក និងពិសារអាហារសម្រន់ | ទាំងអស់គ្នា |
| ១៥៖៣៥ ដល់ ១៦៖៤០ | ការសាកល្បងបង្រៀនមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន<br>• យុទ្ធសាស្ត្រ និងការធានានិរន្តរភាព | **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ១៦៖៤០ ដល់ ១៧៖០០ | ការពិភាក្សាក្រុមធំ ឆ្លុះបញ្ចាំង និងមតិកែលំអអំពីមេរៀន | ទាំងអស់គ្នា |
| ថ្ងៃទី៣៖ ថ្ងៃទី ៣០ សីហា ២០១៨ | | |
| ០៨៖០០ ដល់ ៨០៖៣០ | រំលឹកមេរៀន និងការពិភាក្សាថ្ងៃទី២ | **លោកស្រី ស្រេង សោភ័ណលក្ខិណា**<br>ជំនួយការកម្មវិធីការអភិវឌ្ឍសមត្ថភាព |
| ០៨៖៣០ដល់ ០៩៖៣០ | ការសាកល្បងបង្រៀនមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន<br>• ការពង្រឹងសមត្ថភាពនិងការយល់ដឹង | **លោក ស៊ឹង ទីប៉ូ** អ្នកគ្រប់គ្រងផ្នែកអភិវឌ្ឍន៍សមត្ថភាព |
| ០៩៖៣០ ដល់ ០៩៖៤០ | ការពិភាក្សាក្រុមធំ ឆ្លុះបញ្ចាំង និងមតិកែលំអអំពីមេរៀន | ទាំងអស់គ្នា |
| ០៩៖៤០ ដល់ ០៩៖៥៥ | សម្រាក និងពិសារអាហារសម្រន់ | ទាំងអស់គ្នា |
| ០៩៖៥៥ ដល់ ១១៖៤០ | ការសាកល្បងបង្រៀនមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន<br>• យុទ្ធសាស្ត្រ និងការធានានិរន្តរភាព | **លោក ស៊ឹង ទីប៉ូ** អ្នកគ្រប់គ្រងផ្នែកអភិវឌ្ឍន៍សមត្ថភាព |
| ១១៖៤០ដល់ ១២៖០០ | ការពិភាក្សាក្រុមធំ ឆ្លុះបញ្ចាំង និងមតិកែលំអអំពីមេរៀន | ទាំងអស់គ្នា |
| ១២៖០០ ដល់ ១៣៖៣០ | ពិសារអាហារថ្ងៃត្រង់ | ទាំងអស់គ្នា |
| ១៣៖៣០ ដល់ ១៥៖០០ | ការសាកល្បងបង្រៀនមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន<br>• ភាពជាអ្នកដឹកនាំសហគមន៍ | **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ១៥៖០០ ដល់ ១៥៖២០ | ការពិភាក្សាក្រុមធំ ឆ្លុះបញ្ចាំង និងមតិកែលំអអំពីមេរៀន | ទាំងអស់គ្នា |

DRAFT

| | | |
|---|---|---|
| ១៥៖២០ ដល់ ១៥៖៣៥ | សម្រាក និងពិសារអាហារសម្រន់ | ទាំងអស់គ្នា |
| ១៥៖៣៥ ដល់ ១៦៖៤៥ | ការពិភាក្សាក្រុមតូចៗ ស្តីពី<br>• ផែនការកសាងសមត្ថភាពបន្តអំពីវគ្គបណ្តុះបណ្តាល | **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ១៦៖៤៥ ដល់ ១៧៖០០ | សន្ទរកថាបិទ | តំណាងមកពី អង្គការគ.ស.ក |

**<u>កំណត់ចំណាំ៖</u>** អ្នករៀបចំកម្មវិធីសូមរក្សាសិទ្ធិក្នុងការកែប្រែរបៀបវារៈនៃកម្មវិធីខាងលើ ករណីមានការប្រែប្រួលចាំបាច់។

DRAFT